# សន្ធិសញ្ញាចងស្ពានមេត្រី
# រវាងប្រទេសជប៉ុននឹងប្រទេសកម្ពុជា

ប្រទេសជប៉ុន នឹងព្រះរាជាណាចក្រកម្ពុជា ដោយចង់ឱ្យការរាប់អានបាន ជិតស្និតរវាងគ្នានឹងគ្នាបានព្រមព្រៀងចុះសន្ធិសញ្ញាមិត្តភាពមួយ។

ចំពោះសន្ធិសញ្ញានេះ រដ្ឋទាំងពីរបានតែងតាំងជាអគ្គរាជទូត

រដ្ឋាភិបាលប្រទេសជប៉ុន

ឯកឧត្តម ម៉ាមូរិ ជីគេមិតស៊ឺ រដ្ឋមន្ត្រីក្រសួងការបរទេស

រាជរដ្ឋាភិបាលប្រទេសកម្ពុជា

សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ រដ្ឋមន្ត្រីក្រសួងការបរទេស

អគ្គរាជទូតទាំងពីរ ក្រោយដែលបានប្រាស្រ័យគ្នាហើយ យល់ថាអំណាច សងខាង ត្រឹមត្រូវពេញច្បាប់ ហើយបានសុខចិត្តព្រមព្រៀង គ្នា ធ្វើបទបញ្ញត្តិ ដូចតទៅ៖

## មាត្រា ១

ប្រទេសជប៉ុននឹងប្រទេសកម្ពុជារក្សារវាងគ្នានឹងគ្នា នូវមិត្តភាព នឹង សន្តិភាពដ៏រឹងមាំ ហើយស្ថិតស្ថេរ។

## មាត្រា ២

ឧត្តមភាគីគូសញ្ញានីមួយៗ ត្រូវតែគោរពអធិបតេយ្យភាព ឯករាជ នឹង បូរណភាពប្រទេសរបស់គូសញ្ញាសងខាង។

ឧត្តមភាគីគូសញ្ញាព្រមព្រៀង នឹងរំលត់ដោយសន្តិវិធីនូវការទាស់ទែង ខ្វែងគំនិតគ្នាទាំងឡាយ ដែលអាចនឹងកើតមានឡើង។

## មាត្រា ៣

អ្នកតំណាងខាងផ្លូវទូត និងកុងស៊ុលនៃឧត្តមភាគីគូសញ្ញាត្រូវមានសិទ្ធិនៅក្នុងប្រទេសរបស់គូសញ្ញាខ្លួន ដោយទទួលនូវឯកសិទ្ធិទាំងឡាយ និង អភ័យឯកសិទ្ធិទាំងឡាយ ដែលមានកំរិតក្នុងប្រទេសសំរាប់អ្នកតំណាងខាងផ្លូវទូត និងកុងស៊ុលនៃប្រជាជាតិដែលយោគយល់ជាទីបំផុត។

មាត្រា ៤

ឧត្តមភាគីគូសញ្ញានឹងប្រាស្រ័យទាក់ទងរវាងគ្នានឹងគ្នា ដើម្បីព្រមព្រៀងធ្វើកិច្ចសញ្ញាវិតចំណងសហការឪ្យជិតស្និតខាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងវប្បធម៌។

មាត្រា ៥

ឧត្តមភាគីគូសញ្ញានីមួយៗនឹងខិតខំលៃលកសម្រួលដល់អាណិកជន នៃប្រទេសខាងម្ខាងដែលស្ម័គ្រចង់ចូលមកនៅក្នុងទឹកដីខ្លួន ក្នុងករណីដែលយល់ឃើញថា ការមកនៅនេះនាំឪ្យបាននាំផលប្រយោជន៍រួមគ្នា។

មាត្រា ៦

សន្ធិសញ្ញានេះនឹងត្រូវយកទៅដាក់ជូនរដ្ឋសភាឪ្យសច្ចាប័ន តាមច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសសងខាង។

សន្ធិសញ្ញានេះនឹងត្រូវអនុវត្តមួយខែក្រោយថ្ងៃឆ្លើយឆ្លងលិខិត ដោយមានសច្ចាប័នដែលនឹងត្រូវអនុវត្តជាផរាប ល្គឹកណាបើឧត្តមភាគីគូសញ្ញាណាមួយពុំបានប្រកាសសុំលុបមួយឆ្នាំជាមុនទេ។

ជាបន្ទាល់ក្នុងកិច្ចនេះ អគ្គរាជទូតប្រទេសទាំងពីរបានចុះហត្ថលេខានឹងប្រថាប់ត្រាលើសន្ធិសញ្ញានេះ។

ធ្វើនៅតូក្យូ នៅថ្ងៃទីប្រាំបួន ខែធ្នូ ១៩៥៥ ចំនួនពីរច្បាប់ ជាភាសាជប៉ុន ភាសាខ្មែរ នឹងភាសាបារាំង ដោយទុកភាសាបារាំងជាបន្ទាល់។

ប្រទេសជប៉ុន ប្រទេសកម្ពុជា